# ក្រមរដ្ឋប្បវេណីកម្ពុជា

## សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

## សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

### សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល


| | |
|---|---|
| ករណីទី១ | ទំរង់មូលដ្ឋាននៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល |
| ករណីទី២ | លទ្ធភាពក្នុងការទាមទារឲ្យសងមកខ្លួន |
| ករណីទី៣ | អានុភាពនៃការអនុវត្តសិទ្ធិឧបាទេសកម្ម |
| ករណីទី៤ | ទំនាក់ទំនងជាមួយនឹងម្ចាស់បំណុលផ្សេងទៀត |
| ករណីទី៥ | ទំហំនៃឧបាទេសកម្ម |
| ករណីទី៦ | ករណីកូនបំណុលមានធនធានហរិញ្ញវត្ថុ |
| ករណីទី៧ | សិទ្ធិផ្តាច់មុខ |
| ករណីទី៨ | សិទ្ធិលើបំណុលដែលពាក់ព័ន្ធយ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល |
| ករណីទី៩ | មុនពេលសងនៃសិទ្ធិដែលត្រូវរក្សាការពារ |
| ករណីទី១០ | ការតតាំងនៃកូនបំណុលទី៣ |

## សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍


| | |
|---|---|
| ករណីទី១១ | ទំរង់មូលដ្ឋាននៃសិទ្ធិលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ |
| ករណីទី១២ | របៀបអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ |
| ករណីទី១៣ | ករណីអ្នកដែលទទួលបានផលប្រយោជន៍មិនបានដឹងពីហេតុ |
| ករណីទី១៤ | ករណីមានអ្នកដែលបានទទួលបន្ត |
| ករណីទី១៥ | អ្នកដែលបានទទួលបន្តមិនបានដឹងអំពីស្ថានភាព |
| ករណីទី១៦ | ករណីប្រទានកម្ម |
| ករណីទី១៧ | ករណីកូនបំណុលមានធនធានហិរញ្ញវត្ថុ |
| ករណីទី១៨ | សកម្មភាពដែលមានកម្មវត្ថុមិនមែនជាសិទ្ធិលើទ្រព្យសម្បត្តិ |
| ករណីទី១៩ | អានុភាពនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ |
| ករណីទី២០ | លទ្ធភាពក្នុងការទាមទារឲ្យប្រគល់វត្ថុដែលទទួលបាន |
| ករណីទី២១ | ករណីអនុប្បទានដីជាន់គ្នា |



ខែ មីនា ឆ្នាំ ២០១៤

ការិយាល័យទំនាក់ទំនងអន្តរជាតិនៃក្រសួងយុត្តិនៃប្រទេសជប៉ុន

# ករណីទី ១




[**ករណីសិក្សា**]
A បានឲ្យ B ខ្ចីលុយចំនួន១០០០$។
ទោះបីជាកំឡុងពេលត្រូវសងបានកន្លងហួសក៏ដោយ, ក៏ B នៅតែមិនឃើញសងប្រាក់ចំនួន ១០០០$ នោះទៅ A វិញដែរ។

B មានសិទ្ធិលើបំណុលចំពោះ C ចំនួន ១០០០$ ហើយក្រៅពីនេះ B គ្មានទ្រព្យសម្បត្តិអ្វីផ្សេងទេ ថែមទាំងមានបញ្ហាជីវភាពទៀតផង។
ឧទាហរណ៍ថា B បានគិតថាវាគ្មានប្រយោជន៍នោះទេ ទោះបីជាទទួលបានលុយ ១០០០$ ពី C ក៏ដោយ ក៏ត្រូវយកលុយនោះទៅសង A វិញ ហើយមិនអាចទុកនៅនឹងខ្លួនបាននោះទេ។
ដូច្នេះហើយ B បានទុកចោល ដោយមិនធ្វើការទាមទារឲ្យសងប្រាក់ ១០០០$ ពី C នោះទេ។

តើ A អាចទាមទារឲ្យ C សងលុយ ១០០០$ នោះទៅ B បានដែរឬទេ?

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ ១ កថាខណ្ឌ ១ នៃមាត្រា ៤២២

## ករណីសិក្សាទី ១




**[សេចក្តីបកស្រាយ]**

ដើមឡើយ សិទ្ធិលើបំណុលគឺជាសិទ្ធិដែលម្ចាស់បំណុលអាចអនុវត្តបានតែចំពោះកូនបំណុលប៉ុណ្ណោះ ហើយជាគោលការណ៍ក្រៅពីកូនបំណុលអ្នកណាក៏មិនអាចទាមទារបានដែរ។

ប៉ុន្តែ ករណីដែលដូចនឹងករណីសិក្សាខាងលើនេះ ប្រសិនបើ A មិនអាចទាមទារចំពោះ C បានទេ វាគួរឲ្យអាណិតណាស់ចំពោះ A។

ហេតុនេះហើយបានជា ក្រមរដ្ឋប្បវេណី មាត្រា៤២២ បានបញ្ញត្តិអំពីសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល ដើម្បីឆ្លើយតបទៅនឹងករណីនេះ ។

A អាចអនុវត្តសិទ្ធិឧបាទេសកម្ម ហើយទាមទារ C ឲ្យសងប្រាក់ ១០០០$ ទៅ B បាន។

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ១ កថាខណ្ឌ ១ នៃមាត្រា ៤២២

# ករណីសិក្សាទី ២




**[ករណីសិក្សា]**
ដូចគ្នាទៅនឹងករណីសិក្សាទី១។
B មិនមានបំណងទាមទារឲ្យ C សងលុយ១០០០$ នោះទេ ហើយមិនអាចទាក់ទងបានទៀត។

តើ A អាចទាមទារទៅ C ឲ្យសងប្រាក់ ១០០០$ នោះមកខ្លួនទេ។

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ២ នៃមាត្រា៤២៦

**ករណីទី ២**




[**សេចក្តីបកស្រាយ**]
យើងមិនអាចរំពឹងថា B នឹងទាមទារឲ្យ C សងប្រាក់ ១០០០$ នោះទេ។
ដូច្នេះ ករណីនេះត្រូវនឹង កថាខណ្ឌ២ មាត្រា ៤២៦ «ក្នុងករណីដែលកូនបំណុលមិនអាចទទួលតាវកាលិកពីកូនបំណុលទី៣បាន» A អាចទាមទារទៅ C ឲ្យសងប្រាក់ ១០០០$ មកឲ្យខ្លួនបាន។ ប៉ុន្តែ A អាចត្រឹមតែទទួលប្រាក់ ១០០០$ នោះ ពី C ជំនួស B ប៉ុណ្ណោះ តែមិនអាចប្រើប្រាស់ប្រាក់ ១០០០$ នោះដោយសេរីបានទេ ហើយត្រូវប្រគល់ប្រាក់ ១០០០$ នោះ ត្រលប់ទៅBវិញ។ A អាចរក្សាការពារសិទ្ធិលើបំណុលនូវប្រាក់ ១០០០$ របស់ B បាន តាមរយៈការរឹបអូសការប្រគល់សង ១០០០$ ចំពោះ B។ នេះជាវិធីដើមរបស់សិទ្ធិឧបាទេសកម្ម។

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ២ នៃមាត្រា៤២៦

# ករណីសិក្សាទី ៣




**[ករណីសិក្សា]**

ករណីសិក្សានេះគឺ បន្តពីករណីទី២។

A បានអនុវត្តសិទ្ធិឧបាទេសកម្មដោយម្ចាស់បំណុល ហើយទទួលបានប្រាក់ ១០០០$ ពី C ពេលនេះ A កំពុងគ្រប់គ្រងប្រាក់ ១០០០$ នោះក្នុងដៃ។

ក្រោយមក តើ B អាចទាមទារឲ្យ C សងប្រាក់ ១០០០$ បានទេ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ នៃមាត្រា ៤២៦

**ករណីទី ៣**




**[សេចក្តីបកស្រាយ]**
ក្នុងករណីដែលម្ចាស់បំណុលអនុវត្តសិទ្ធិឧបាទេសកម្ម អានុភាពត្រូវកើតឡើងចំពោះកូនបំណុល។
មានន័យថា អានុភាពនៃការសងប្រាក់ ១000$ ពី C ទៅ A ត្រូវមានអានុភាពចំពោះ B ផងដែរ
ដូច្នេះ សិទ្ធិលើបំណុលរបស់ B ចំពោះ C ត្រូវរលត់តាមរយៈការសង។
ហេតុនេះ B មិនអាចទាមទារឲ្យ C សងប្រាក់ ១000$ បានទេ។

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ១ នៃមាត្រា ៤២៦

## ករណីទី ៤




**[ករណីសិក្សា]**

ករណីសិក្សានេះ បន្តពីករណីទី២ ខាងលើ។

A អនុវត្តសិទ្ធិឧបាទេសរបស់ម្ចាស់បំណុល ហើយទទួលយកប្រាក់ ១០០០$ ពី C មកគ្រប់គ្រងក្នុងដៃ។ ដោយសារតែ A មានសិទ្ធិត្រឹមតែទទួលយកប្រាក់ ១០០០$ ពី C ជំនួសឲ្យ B ប៉ុណ្ណោះ ដូច្នេះ A ត្រូវតែប្រគល់ប្រាក់នោះត្រលប់ទៅ B វិញ។

និយាយត្រលប់មកវិញគឺ B មានសិទ្ធិទាមទារឲ្យសងត្រលប់មកវិញនូវប្រាក់ ១០០០$ ចំពោះ A។

ហើយ ក្រៅពីម្ចាស់បំណុល A, B មានម្ចាស់បំណុលផ្សេងទៀត គឺ X និង Y។

តើ A អាចធ្វើការទូទាត់ជាមួយ B ដោយយកប្រាក់ ១០០០$ នោះ មកធ្វើជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់ឯងបានដែរ ឬទេ?

[មាត្រាប្រើប្រាស់]

## ករណីសិក្សាទី ៤




**[សេចក្តីបកស្រាយ]**

សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលគឺជាប្រព័ន្ធដែលមានគោលបំណងការពារទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីចែកទៅម្ចាស់បំណុលទាំងអស់ ហើយមិនមែនជាប្រព័ន្ធដែលអនុញ្ញាតឲ្យម្ចាស់បំណុលម្នាក់ទទួលបានតែឯងនោះទេ។

មានន័យថា A មិនអាចធ្វើការទូទាត់បានទេ ហើយត្រូវប្រគល់ប្រាក់ ១០០០$ នោះត្រលប់ទៅ B វិញ។

នៅពេលដែល A ប្រគល់ត្រលប់នូវលុយ ១០០០$ នោះទៅ B វិញ ប្រាក់ត្រូវបែកចែកទៅតាមភាគនៃសិទ្ធិលើបំណុលគឺ X ៦០០$, Y ៣០០$ និង A ១០០$។

[មាត្រាប្រើប្រាស់]

# ករណីទី ៥




[**ករណីសិក្សា**]
ករណីសិក្សានេះ គឺដូចគ្នាទៅនឹងករណីទី១ ផងដែរ ដែលជាករណីសិក្សាធម្មតា។
ប៉ុន្តែ B មានសិទ្ធិលើបំណុលចំពោះ C ចំនួន ២០០០$។

តើ A អនុវត្តសិទ្ធិឧបាទេសកម្ម ហើយអាចទាមទារប្រាក់ចំនួនប៉ុន្មានពី C ?

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ១ កថាខណ្ឌ ១ នៃមាត្រា៤២២

## ករណីទី ៥




**[សេចក្តីបកស្រាយ]**

សិទ្ធិឧបាទេសកម្មគឺជាសិទ្ធិដែលមានអនុភាពខ្លាំងអនុវត្តទៅលើសិទ្ធិរបស់អ្នកដទៃ ដូច្នេះ សិទ្ធិនេះមិនអាចអនុវត្តបានដោយគ្មានកំណត់ព្រំដែននៃការអនុវត្តនោះទេ ហេតុនេះហើយ ម្ចាស់បំណុលឧបាទេសកម្មអាចអនុវត្តបានត្រឹមតែទំហំនៃប្រាក់ដែលជាសិទ្ធិលើបំណុលរបស់ខ្លួនប៉ុណ្ណោះ។

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ១ មាត្រា ៤២២

ក្នុងមាត្រាមិនមានបញ្ញត្តិនោះទេ តែអាចសន្និដ្ឋានបានតាមរយៈការបកស្រាយ។

**ករណីទី ៦**




[**ករណីសិក្សា**]
ករណីសិក្សានេះដូចទៅនឹងករណីទី ១ ដែរ ហើយជាករណីសិក្សាដែលសាមញ្ញបំផុត។
ប៉ុន្តែ B មានប្រាក់ក្នុងដៃ ដែលជាប្រាក់សន្សំលើសពី ១០០០០$។

តើ A អាចអនុវត្តសិទ្ធិឧបាទេសកម្មបានដែរឬទេ?

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ ១ កថាខណ្ឌ ១ នៃមាត្រា ៤២២

# ករណីទី ៦




**[សេចក្តីបកស្រាយ]**
ក្នុងករណីដែលកូនបំណុលមានទ្រព្យសម្បត្តិគ្រប់គ្រាន់ គឺម្ចាស់បំណុលអាចទទួលបានការសងពីទ្រព្យសម្បត្តិនោះបាន ហេតុនេះហើយ មិនអាចអនុវត្តសិទ្ធិឧបាទេសកម្មបានទេ ដោយសារតែ មិនសបស្រេបទៅនឹងអត្ថន័យថា「ករណីចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន」។

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ ១ កថាខណ្ឌ ១ នៃមាត្រា ៤២២

**ករណីទី ៧**




**[ករណីសិក្សា]**

ប្រពន្ធ B និង ប្តី C បានលែងលះគ្នា។

ប្រពន្ធ B គឺមានសិទ្ធិទាមទារឲ្យបែងចែងទ្រព្យសម្បត្តិចំនួន ១០០០$ ចំពោះប្តី C។

តើ A អាចអនុវត្តសិទ្ធិឧបាទេសកម្មបានដែរ ឬទេ?

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ២ កថាខណ្ឌ ១ នៃមាត្រា ៤២២

**ករណីទី ៧**




**[សេចក្តីបកស្រាយ]**
ទោះបីជា ប្រពន្ធទាមទារ ឬក៏ មិនទាមទារឲ្យបែងចែកទ្រព្យសម្បត្តិជាមួយប្តីដែលបានលែងលះគ្នា គឺជាបញ្ហាឯកជនសុទ្ធសាធ ហើយអ្នកផ្សេងមិនអាចចូលមកជ្រៀតជ្រែកបាននោះទេ។ ហេតុនេះ សិទ្ធិទាមទារឲ្យបែកចែងទ្រព្យសម្បត្តិដែលកើតឡើងដោយសារការលែងលះគ្នា គឺជាសិទ្ធិផ្តាច់មុខដែលមានតែសាមីខ្លួនប៉ុណ្ណោះអាចអនុវត្តបាន។
ដូចនេះ A មិនអាចអនុវត្តសិទ្ធិឧបាទេសកម្មបានទេ។

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ ២ កថាខណ្ឌ ១ នៃមាត្រា ៤២២

## ករណីទី ៨ ៖ សិទ្ធិលើបំណុលដែលពាក់ព័ន្ធ យ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល




**[ករណីសិក្សា]**

A បានរងរបួសដោយសារតែប៉ះទង្គិចជាមួយរថយន្តរបស់ B ហេតុនេះហើយទើប A មានសិទ្ធិទាមទារសំណងការខូចខាតពី B ចំនួន ១០០០$។

ដោយសារតែ B មានធានារ៉ាប់រងរថយន្ត ដូច្នេះហើយ B មានសិទ្ធិទាមទារថ្លៃធានារ៉ាប់រងពីក្រុមហ៊ុន C បាន។

B ជាអ្នកមាន ហើយមានប្រាក់សន្សំលើសពី ១០០០០$ ទៀត។

តើ A អាចអនុវត្តសិទ្ធិឧបាទេសកម្មទៅក្រុមហ៊ុនធានារ៉ាប់រង C បានដែរ ឬទេ?

ប្រសិនបើ A អាចអនុវត្តសិទ្ធិឧបាទេសកម្មបាន តើ A អាចយកប្រាក់ ១០០០$ ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង C មកធ្វើជារបស់ខ្លួនបានដែរ ឬទេ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ២ នៃមាត្រា ៤២២

## ករណីទី ៨ ៖ សិទ្ធិលើបំណុលដែលពាក់ព័ន្ធយ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល




[សេចក្តីបកស្រាយ]
សិទ្ធិទាមទារប្រាក់ធានារ៉ាប់រងរបស់ B គឺជាសិទ្ធិដែល A ត្រូវអនុវត្តដើម្បីទាមទារសំណងការខូចខាតពី B។ ក្នុងករណីបែបនេះ វាសមស្របទៅនឹងកថាខណ្ឌ ២ នៃមាត្រា ៤២២ ｢សិទ្ធិលើបំណុលដែលមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសិទ្ធិរបស់កូនបំណុល｣។
ក្នុងកថាខណ្ឌ ២ បានបញ្ញត្តិថា ｢ក្នុងករណីចាំបាច់ដើម្បីទទួលបានការបំពេញចំពោះសិទ្ធិលើបំណុលរបស់ខ្លួន｣ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិឧបាទេសកម្មបាន។ ហើយភាពចាំបាច់ដែលត្រូវរក្សាការពារមិនមែនជាលក្ខខណ្ឌទៀតនោះទេ ហេតុនេះហើយ កូនបំណុលមានធនធានហិរញ្ញវត្ថុក៏ដោយ ក៏អាចអនុវត្តសិទ្ធិឧបាទេសកម្មបានដែរ។

ហើយប្រាក់ធានារ៉ាប់រង ១០០០$ ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង C ចុងក្រោយបំផុត A នឹងទទួលបានប្រាក់នោះដដែល ហេតុនេះហើយ A អាចទុកក្នុងដៃរបស់ខ្លួនដោយមិនចាំបាច់សងទៅ B វិញនោះទេ។
ដូច្នេះហើយ បានជាវាក្យខណ្ឌ ២ នៃមាត្រា ៤២៧ បានបញ្ញត្តិបែបនេះ។
[មាត្រាប្រើប្រាស់]

# ករណីទី ៩




**[ករណីសិក្សា]**

ករណីសិក្សានេះដូចទៅនឹងករណីទី១ ដែរ ហើយជាករណីសិក្សាដែលសាមញ្ញ។
ប៉ុន្តែ ពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ A ចំពោះ B គឺនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០១៤ ហេតុនេះហើយ នៅចំណុចពេលនៃថ្ងៃទី ១៤ ខែ មីនា គឺនៅមិនទាន់ដល់ពេលកំណត់ត្រូវសងនៅឡើយទេ។

តើ A អាចអនុវត្តសិទ្ធិឧបាទេសកម្មបានដែរ ឬទេ?

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ២ នៃមាត្រា ៤២៣

# ករណីទី ៩
# មុនពេលសងនៃសិទ្ធិដែលត្រូវរក្សាការពារ




**[សេចក្តីបកស្រាយ]**

មុនពេលកំណត់សងនៃសិទ្ធិលើបំណុលដែលត្រូវរក្សាការពារ ម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិឧបាទេសកម្មបានឡើយ។

ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិឧបាទេសកម្មបាន ប្រសិនបើមានការអនុញ្ញាតពីតុលាការ។ហើយទោះបីជាមិនទាន់ដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏អាចអនុវត្តសិទ្ធិឧបាទេសកម្មដើម្បីរក្សាការពារបាន។

សកម្មភាពរក្សាការពារមានដូចជា ករណីទាមទារឲ្យសង ដើម្បីផ្អាកអាជ្ញាយុកាលជាដើម ( ចំណុច ក នៃមាត្រា ៤៨៩)

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៣

**ករណីទី ១០**
**ការតតាំងនៃកូនបំណុលទី ៣**




[**ករណីសិក្សា**]
ករណីសិក្សានេះដូចទៅនឹងករណីទី១ ដែរ  ហើយជាករណីសិក្សាដែលសាមញ្ញ។
ប៉ុន្តែ C មានសិទ្ធិលើបណុល ១០០០$ ចំពោះ B។
A បានអនុវត្តសិទ្ធិឧបាទេសកម្ម ហើយទាមទារឲ្យ C សងប្រាក់ ១០០០$។

តើ C អាចទាមទារចំពោះ A ឲ្យទូទាត់បានដែរ ឬទេ?

[មាត្រាប្រើប្រាស់]
មាត្រា ៤២៤

**ករណីទី ១០**
**ការតតាំងនៃកូនបំណុលទី ៣**




**[សេចក្ដីបកស្រាយ]**
C អាចអះអាងចំពោះ A នូវសិទ្ធិតតាំងដែលខ្លួនមានចំពោះ B បាន។

[មាត្រាប្រើប្រាស់]
មាត្រា ៤២៤

**ករណីទី ១១ ៖ ទំរង់មូលដ្ឋាននៃសិទ្ធិលុបចោល**
**អំពើដែលនាំឲ្យខូចខាតផលប្រយោជន៍**




**[ករណីសិក្សា]**
A មានសិទ្ធិលើបំណុល ១០០០$ ចំពោះ B។
ទ្រព្យសម្បត្តិរបស់ B គឺគ្មានទ្រព្យសម្បត្តិអ្វីផ្សេង ក្រៅពីដីមួយតម្លៃ ១០០០$ នោះទេ។
A រំពឹងថានឹង រឹបអូសដីរបស់ B មកលក់ដោយបង្ខំ ដើម្បីសងបំណុលរបស់ខ្លួន។
B ហើយនឹង C ជាមិត្តភិក្តនឹងគ្នា ហើយ B បានប្រាប់ទៅ C នូវស្ថានភាពទាំងអស់ដូចជា បំណុលដែលខ្លួនមានចំពោះ A និង ការបារម្ភថា A នឹងរឹបអូសយកដីរបស់ខ្លួនជាដើម។
B បានគិតថា ដីរបស់ខ្លួនគង់តែត្រូវ A រឹបអូសដដែល ដូច្នេះ លក់ឲ្យ C ដែលជាមិត្តភិក្តក្នុងតម្លៃថោកល្អជាង ហើយពេលនោះ A ក៏បានលក់ដីរបស់ខ្លួនទៅ C ក្នុងតម្លៃ ៥០០$ និង ចុះបញ្ជីផ្ទេរទៅ C រួចរាល់ទៀតផង។
តើ A ប្រើវិធីសាស្ត្របែបណាទើបអាចយកបាន?

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ១ នៃមាត្រា ៤២៨

**ករណីទី ១១ ៖ ទំរង់មូលដ្ឋាននៃសិទ្ធិលុបចោលអំពើ ដែលនាំឲ្យខូចខាតផលប្រយោជន៍**




**[សេចក្តីបកស្រាយ]**

សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍អាចទទួលស្គាល់បានលុះត្រាតែ ① សកម្មភាពនោះមើលជាសច្ចានុម័តទៅគឺជាសកម្មភាព (សកម្មភាពធ្វើឲ្យខូចខាត) ដែលធ្វើឲ្យប៉ះពាល់ដល់ម្ចាស់បំណុល និង ② កូនបំណុលបានដឹងថាសកម្មភាពនោះជាសកម្មធ្វើឲ្យខូចខាត។ ដើម្បីអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍នោះចំពោះ អ្នកទទួលផលប្រយោជន៍បាន លុះត្រាតែ អ្នកទទួលផលប្រយោជន៍បានដឹងថាសកម្មភាពនោះជាសកម្មភាពដែលធ្វើឲ្យខូចខាតផលប្រយោជន៍។

ក្នុងករណីសិក្សានេះ ដោយសារតែដីតម្លៃ ១០០០$ លក់ក្នុងតម្លៃ ៥០០$ ជាហេតុធ្វើឲ្យទ្រព្យសម្បត្តិរបស់ A ធ្លាក់ចុះ ដូច្នេះ ការទិញលក់រវាង B និង C ជាសកម្មភាពដែលធ្វើឲ្យខូចខាតជាសច្ចានុម័ត។ ហើយ ទាំង B ទាំង C សុទ្ធតែបានដឹងថាសកម្មភាពនោះជាសកម្មភាពដែលធ្វើឲ្យខូចខាត។ ហេតុនេះ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតប្រយោជន៍ ដើម្បីលុបចោលនូវកិច្ចសន្យាទិញលក់រវាង B និង Cបាន ហើយ A អាចទាមទារឲ្យ C ប្រគល់ដី និង ប្រគល់ការចុះបញ្ជីត្រលប់មក B វិញបាន។

[មាត្រាប្រើប្រាស់]

# ករណីទី ១២
# របៀបអនុវត្តសិទ្ធិលុបចោលអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍




**[ករណីសិក្សា]**

ករណីសិក្សានេះ ដូចគ្នានឹងករណីទី ១១ ផងដែរ។

មានន័យថា ករណីដែល B បានលក់ដីក្នុងតម្លៃ ៥០០$ ទៅឲ្យ C ហើយ C បានដឹងពីស្ថានភាពទាំងអស់។ ក្នុងករណីបែបនេះ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន។

បើដូច្នេះ តើ A តើអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ដោយរបៀបណា? តើអាចទាមទារដោយផ្ទាល់ចំពោះ C បាន ឬទេ? តើចាំបាច់ត្រូវទាមទារទៅតុលាការ ឬទេ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ នៃមាត្រា ៤២៨

**ករណីទី ១២**
**របៀបអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍**




**[សេចក្តីបកស្រាយ]**
ក្នុងករណីអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ ចាំបាច់ត្រូវតាមទាមទារទៅតុលាការ។
ពីព្រោះតែ ប្រពន្ធ័នេះមានអានុភាពយ៉ាងខ្លាំង ដែលអាចលុបចោលនូវសកម្មភាពគតិយុត្តិរបស់អ្នកដទៃ ហេតុនេះហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយម៉ត់ចត់។

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ១ នៃ មាត្រា ៤២៨

[ឯកសារយោង]
សិទ្ធិលុបចោលរបស់ម្ចាស់បំណុលមិនចាំបាច់ត្រូវទាមទារទៅតុលាការនោះទេ គឺអាចទាមទារដោយផ្ទាល់ទៅភាគីម្ខាងទៀតបាន។

**ករណីទី ១៣**

**ករណីអ្នកដែលទទួលបានផលប្រយោជន៍មិនបានដឹងពីស្ថាន**




[**ករណីសិក្សា**]

ករណីសិក្សានេះ ដូចគ្នានឹងករណីទី ១១ ផងដែរ។

ប៉ុន្តែ B និង C មិនមែនជាមិនភក្តិនឹងគ្នាទេ ហើយ C មិនបានដឹងអំពីស្ថានភាពរបស់ A និង B។

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បានដែរ ឬទេ?

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃ មាត្រា ៤២៨

## ករណីទី ១៣
## ករណីអ្នកដែលទទួលបានផលប្រយោជន៍មិនបានដឹងពីស្ថាន




**[សេចក្ដីបកស្រាយ]**

ប្រសិនបើ C មិនបានដឹងអំពីស្ថានភាពរវាង A និង B នោះទេ A មិនអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បានទេ។

ក្នុងករណីបែបនេះ C មិនមានកំហុសនោះទេ ហើយចាំបាច់ត្រូវការពារការជឿជាក់របស់ C ។

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៨

## ករណីទី ១៤
## ករណីមានអ្នកទទួលបន្ត




**[ករណីសិក្សា]**

ករណីសិក្សានេះ ដូចគ្នានឹងករណីទី ១១ ផងដែរ។
មានន័យថា A មានសិទ្ធិលើបំណុលចំនួន ១០០០$ ចំពោះ B ហើយ B បានលក់ដីនោះ ក្នុងតម្លៃ ៥០០$ ទៅ C។ ក្រោយមក C បានលក់ដីនោះទៅអ្នកទទួលបន្ត D ក្នុងតម្លៃ ៧០០$។
D បានដឹងអំពីស្ថានភាពរវាង A និង B ហើយ បានដឹងថាការទិញលក់ដីរបស់ B និង C ជាអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ផងដែរ។

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ដែរ ឬទេ?
ប្រសិនបើអាច តើ A អាចទាមទារអ្វីខ្លះ ចំពោះ C និង D ?

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ១ និង វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៨

**ករណីទី ១៤**




**[សេចក្តីបកស្រាយ]**

A អាចលុបចោលកិច្ចសន្យាលក់ទិញរវាង C និង D ហើយទាមទារឲ្យអ្នកទទួលបន្ត D ប្រគល់មកវិញនូវ ដី និង ការចុះបញ្ជី ត្រលប់មក B វិញ។

ពីព្រោះ ដីមិនស្ថិតក្នុងដៃ របស់ C ហេតុនេះហើយ C មិនអាចប្រគល់ដីត្រលប់មក B បានទេ។ ដូច្នេះ A អាចលុបចោលកិច្ចសន្យាលក់ទិញរវាង B និង C ហើយទាមទារឲ្យ C ប្រគល់ប្រាក់ថ្លៃដីចំនួន ១០០០$ មក B វិញ។

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ និង វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៨

**ករណីទី ១៥**
**ករណីអ្នកទទួលបន្តមិនបានដឹងអំពីស្ថានភាព**




[**ករណីសិក្សា**]

ករណីសិក្សានេះ ដូចគ្នាទៅនឹងករណីទី ១៤ ផងដែរ។

ប៉ុន្តែ D មិនបានដឹងអំពីស្ថានភាពរវាង A និង B ទេ។

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន ឬទេ?

ប្រសិនបើអាច តើ A ទាមទារអ្វីចំពោះ C និង D ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ និង វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៨

## ករណីទី ១៥
## ករណីអ្នកទទួលបន្តមិនដឹងអំពីស្ថានភាព




**[សេចក្ដីបកស្រាយ]**

អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន ឬមិនបាន គឺអាស្រ័យទៅលើ ភាគីនីមួយៗ។

A អាចអនុវត្តបានចំពោះអ្នកដែលដឹងអំពីស្ថានភាព C តែមិនអាចអនុវត្តចំពោះអ្នកដែលមិនបានដឹងស្ថានភាព D នោះទេ។

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ និង វាក្យខណ្ឌ ១ កថាខណ្ឌ ២ នៃមាត្រា ៤២៨

# ករណីទី ១៦




**[ករណីសិក្សា]**

B បានឲ្យដីនោះទៅ C (ប្រទានកម្ម)។ B និង C មិនមែនជាមិត្តភក្តិនឹងគ្នាទេ ហើយ C មិនបានដឹងអំពីស្ថានភាពអ្វីទាំងអស់រវាង A និង B។

A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន ឬទេ?

[មាត្រាប្រើប្រាស់]

វាក្យខណ្ឌ ២ កថាខណ្ឌ ២ នៃមាត្រា ៤២៨

# ករណីទី ១៦
# ករណីប្រទានកម្ម




[**សេចក្តីបកស្រាយ**]
ដោយសារ C ទទួលបានដោយប្រទានកម្ម និងមិនមានបង់តម្លៃតប ដូចនេះ C ជាអ្នកទទួលផលប្រយោជន៍ដោយមិនបង់ថ្លៃ។
ក្នុងករណីនេះ ទោះបីជាទទួលស្គាល់ការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ក៏ដោយ ក៏មិនធ្វើឲ្យខូចខាតផលប្រយោជន៍ត្រឹមត្រូវរបស់ C ដែរ។
មានន័យថា ទោះបីជា C មិនបានដឹងអំពីស្ថានភាពក៏ដោយ ក៏ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បានដែរ។

[មាត្រាប្រើប្រាស់]
វាក្យខណ្ឌ ២ កថាខណ្ឌ ២ នៃមាត្រា ៤២៨

# ករណីទី ១៧




**[ករណីសិក្សា]**

ករណីសិក្សានេះ ដូចគ្នានឹងករណីទី ១១ ផងដែរ។
មានន័យថា B លក់ដីទៅឲ្យ C ក្នុងតម្លៃ ៥០០$ ហើយ C បានដឹងអំពីស្ថានភាព។
ប៉ុន្តែ B ជាអ្នកមាន ហើយក្រៅពីដីនោះ គាត់នៅមានប្រាក់សន្សំ ១០០០០$ ទៀត។

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន ឬទេ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ នៃមាត្រា ៤២៨

## ករណីទី ១៧
## ករណីកូនបំណុលមានធនធានហិរញ្ញវត្ថុ




**[សេចក្តីបកស្រាយ]**

សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ គឺជាប្រព័ន្ធដែលការពារមិនអាចកូនបំណុលក្លាយទៅជាគ្មានធនធានហិរញ្ញវត្ថុ ដើម្បីធានាថាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលពិតជាអាចសង

បាន។

មានន័យថា បើកូនបំណុលមានធនធាហិរញ្ញវត្ថុ គឺមិនអាចអនុវត្តបាននោះទេ។

ចំណុចនេះមិនមានបញ្ញត្តិច្បាស់លាស់ក្នុងមាត្រា ៤២៨នោះទេ ប៉ុន្តែ ពាក្យថា «ធ្វើឲ្យខូចខាតប្រយោជន៍ដល់ម្ចាស់បំណុល» គឺបូករួមទាំងអត្ថន័យថា កូនបំណុលក្លាយជាគ្មានធនធានហិរញ្ញវត្ថុផងដែរ។

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ១ នៃមាត្រា ៤២៨

**ករណីទី ១៨**
**សកម្មភាពដែលមានកម្មវត្ថុមិនមែនជាសិទ្ធិលើទ្រព្យសម្បត្តិ**




**[ករណីសិក្សា]**

A មានសិទ្ធិលើបំណុល ១០០០$ ចំពោះ B។

ទ្រព្យសម្បត្តិរបស់ B គឺមានតែប្រាក់ ១០០០$ ប៉ុណ្ណោះ។

B និង C បានរៀបការជាមួយគ្នា។

C គឺជាស្ត្រីដែលមានកូន ៣ នាក់ ហើយ ជាមនុស្សមានជីវភាពក្រីក្រខ្លាំង។

B បានចំណាយប្រាក់ ១០០០$ ដើម្បីចិញ្ចឹមបីបាច់ C និង កូនៗ។

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ ហើយលុបការរៀបអាពាហ៍ពិពាហ៍រវាង B និង C បាន ឬទេ?

[មាត្រាប្រើប្រាស់]

កថាខណ្ឌ ៣ នៃមាត្រា ៤២៨

**ករណីទី ១៨**
**សកម្មភាពដែលមានកម្មវត្ថុមិនមែនជាសិទ្ធិលើទ្រព្យសម្បត្តិ**




**[សេចក្តីបកស្រាយ]**
សកម្មភាពទាក់ទងជាមួយឋានៈ ដូចជា ការរៀបការជាដើម គឺជារឿងដែលត្រូវសម្រេចដោយឆន្ទៈផ្ទាល់ខ្លួនរបស់សាមីខ្លួន ដោយបុគ្គលដទៃទៀតមិនអាចជ្រៀតជ្រែកបានឡើយ។
មានន័យថា សកម្មភាពបែបនេះមិនមែនជាកម្មវត្ថុនៃសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ទេ។

[មាត្រាប្រើប្រាស់]
កថាខណ្ឌ ៣ នៃមាត្រា ៤២៨

## ករណីទី ១៩ ៖ អានុភាពនៃសិទ្ធិលុបចោលនូវអំពើ ដែលនាំឲ្យខូចខាតផលប្រយោជន៍




**[ករណីសិក្សា]**

ករណីសិក្សានេះ ដូចគ្នានឹងករណីទី ១១ ផងដែរ។

មានន័យថា ករណីដែល B បានលក់ដីក្នុងតម្លៃ ៥០០$ ទៅឲ្យ C។

A បានអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតប្រយោជន៍ ដើម្បីលុបកិច្ចសន្យាលក់ទិញរវាង B និង C ហើយ ដី និង ការចុះបញ្ជីបានផ្ទេរត្រលប់ពី C ទៅ B វិញ។

A បានរឹបអូស និង លក់ដោយបង្ខំនូវដីរបស់ B ហើយទទួលបានប្រាក់ ១០០០$។

ក្រៅពីម្ចាស់បំណុល A, B នៅមានម្ចាស់បំណុលផ្សេងទៀតគឺ X ៦០០០$ និង Y ៣០០០$។

តើ A អាចយកប្រាក់ ១០០០$ ដែលបានពីការលក់ដីនោះ មកធ្វើលទ្ធកម្មម្នាក់ឯងបានទេ?

[មាត្រាប្រើប្រាស់]

មាត្រា ៤៣១

# ករណីទី ១៩ ៖ អានុភាពនៃសិទ្ធិលុបចោលនូវអំពើ ដែលនាំឲ្យខូចខាតផលប្រយោជន៍




**[សេចក្តីបកស្រាយ]**

សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ គឺជាប្រព័ន្ធសម្រាប់ម្ចាស់បំណុលទូទៅ ដូច្នេះ មិនអាចយកជាកម្មសិទ្ធិម្នាក់ឯងបានទេ។

X Y និង A ត្រូវទទួលបានចំណែកតាមសមាមាត្រនៃសិទ្ធិលើបំណុលរបស់ខ្លួន គឺ ៦០០$, ៣០០$ និង ១០០$។

[មាត្រាប្រើប្រាស់]

មាត្រា ៤៣១

## ករណីទី ២០
## លទ្ធភាពក្នុងការទាមទារឲ្យប្រគល់វត្ថុដែលទទួលបាន




**[ករណីសិក្សា]**

A មានសិទ្ធិលើបំណុល ១០០០$ ចំពោះ B។

ទ្រព្យសម្បត្តិរបស់ B មានតែទ្រព្យសម្បត្តិ ១០០០$ ប៉ុណ្ណោះ។

B បានប្រទានកម្មប្រាក់ ១០០០$ ឲ្យទៅ C ហើយក៏បាត់ខ្លួនទៅ។

ដូចនេះ A បានអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ ហើយលុបចោលកិច្ចសន្យាប្រទានកម្មរវាង B និង C។

ដោយសារតែ B បានបាត់ខ្លួន ជាហេតុធ្វើឲ្យ C ស្ថិតក្នុងស្ថានភាពដែលមិនអាចប្រគល់ប្រាក់ ១០០០$ នោះត្រលប់ទៅ B វិញបាន។

ក្រៅពីម្ចាស់បំណុល A, B នៅមានម្ចាស់បំណុលផ្សេងទៀតគឺ X ៦០០០$ និង Y ៣០០០$។

តើ A អាចទាមទារឲ្យ C ប្រគល់ប្រាក់ ១០០០$ នោះមកខ្លួនបានទេ?

[មាត្រាប្រើប្រាស់]

# ករណីទី ២០




[សេចក្តីបកស្រាយ]
សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតនូវផលប្រយោជន៍ គឺជាប្រព័ន្ធសម្រាប់ម្ចាស់បំណុលទូទៅ ដូច្នេះហើយ ទោះបីជា B បាត់ខ្លួន ហើយមិនអាចទទួលយកប្រាក់ក៏ដោយ ក៏ A មិនអាចទាមទារឲ្យប្រគល់ប្រាក់នោះមកខ្លួនដែរ។
ក្នុងករណីបែបនេះ A អាចទាមទារឲ្យ C តំកល់ប្រាក់ ១០០០$ នោះបាន។ ប្រាក់ ១០០០$ ដែលតំកល់នោះ ចុងក្រោយបំផុតគឺត្រូវបែងទៅសមាមាត្រនៃសិទ្ធិលើបំណុល គឺ X ៦០០$, Y ៣០០$ និង A ១០០$។

[មាត្រាប្រើប្រាស់]
មាត្រា ៤៣០

## ករណីសិក្សា ២១
## ករណីអនុប្បទានដីជាន់គ្នា




**[ករណីសិក្សា]**

B មានកម្មសិទ្ធិលើដី។ B បានចុះកិច្ចសន្យាលក់ដីតម្លៃ ១០០០$ ជាមួយ A ។(①) ហើយ B បានបង់ប្រាក់ ១០០០$ ទៅ A។(②)តាមរយៈនេះ ធ្វើឲ្យ A មានសិទ្ធិទាមទារឲ្យ B ប្រគល់ដី និង ផ្ទេរការចុះបញ្ជី។(③) បន្ទាប់មក B ក៏បានចុះកិច្ចសន្យាលក់ដីតម្លៃ ១០០០$ ជាមួយ C ដូចគ្នា។ (④) ហើយ B បានប្រគល់ដីនោះព្រមទាំងការផ្ទេរការចុះបញ្ជីទៅ C ។(⑤)

តើ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ ដើម្បីលុបចោលកិច្ចសន្យាទិញលក់រវាង A និង B ហើយទាមទារឲ្យ C ប្រគល់ដី និង ការចុះបញ្ជីត្រលប់មក B វិញបាន ឬទេ?

[អ្វីទៅជាបញ្ហា?]

ដើមឡើយ សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ គឺជាប្រព័ន្ធដែលការពារទ្រព្យសម្បត្តិរបស់កូនបំណុល សំរាប់ម្ចាស់បំណុលទូទៅ។ មានន័យថា មានតែម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលជាប្រាក់ចំពោះកូនបំណុលប៉ុណ្ណោះទេ ដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន។

ប៉ុន្តែ ករណីសិក្សានេះ គឺករណីដែល A មានសិទ្ធិលើបំណុលក្រៅពីប្រាក់ចំពោះ B ដូច្នេះហើយ បញ្ហាត្រង់ថា តើករណីបែបនេះអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចផលប្រយោជន៍បាន ឬទេ?

## ករណីសិក្សា ២១




**[សេចក្តីបកស្រាយ]**

នៅពេលដែល B បានផ្ទេរការចុះបញ្ជីទៅ C ធ្វើឲ្យ C មានអានុភាពជាង A លើបញ្ហាដី ហើយ A មិនអាចធ្វើលទ្ធកម្មដីនោះបានទេ។

មានន័យថា សិទ្ធិទាមទារឲ្យប្រគល់ដី និង ផ្ទេរការចុះបញ្ជីរបស់ A ក្លាយជាអលទ្ធភាពក្នុងការអនុវត្ត ហើយប្រែក្លាយទៅជាសិទ្ធិទាមទារសំណងការខូចខាតវិញ។ ហើយនេះជាសិទ្ធិលើបំណុលដែលមានគោលបំណងជាប្រាក់។ តាមរយៈនេះ A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន។

[អ្វីទៅជាបញ្ហា?]

ដើមឡើយ សិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ គឺជាប្រព័ន្ធដែលការពារទ្រព្យសម្បត្តិរបស់កូនបំណុល សំរាប់ម្ចាស់បំណុលទូទៅ។ មានន័យថា មានតែម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលជាប្រាក់ចំពោះកូនបំណុលប៉ុណ្ណោះទេ ដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍បាន។

ប៉ុន្តែ ករណីសិក្សានេះ គឺករណីដែល A មានសិទ្ធិលើបំណុលក្រៅពីប្រាក់ចំពោះ B ដូច្នេះហើយ បញ្ហាត្រង់ថា តើករណីបែបនេះអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចផលប្រយោជន៍បាន ឬទេ?